# តើគ្រួសារស្ត្រីមេគ្រួនៅជនបទ ទាំងអស់សុទ្ធតែក្រ រឺយ៉ាងណា?

*លោក Brett M. Ballard និងលោកស្រី Ingrid FitzGerald ពិនិត្យពីទំនាក់ទំនងរវាងភេទនៃមេគ្រួសារនៅជនបទ ហើយនិងអថេរសំខាន់ៗមួយចំនួនទាក់ទិននឹងបញ្ហាដីធ្លី ដូចជា ទំហំដីកាន់កាប់ លទ្ធកម្មដីធ្លី ទ្រព្យសម្បត្តិនិងចំណូលគ្រួសារ ធនធានកំលាំងពលកម្ម ការមានស្រូវអង្ករហូបគ្រប់គ្រាន់ និងវិនិយោគលើផលិតកម្មស្រូវ ។**

ឯកសារអន្តរជាតិ និងឯកសារទាក់ទិននឹងកម្ពុជាបានបង្ហាញថា គ្រួសារស្ត្រីមេគ្រួជាទូទៅច្រើនតែក្រីក្រ ។ ប៉ុន្តែភស្តុតាងថ្មីៗបានពីការសិក្សាជាច្រើនរបស់វិទ្យាស្ថាន CDRI បានបង្ហាញផ្ទុយពីនេះ ហើយអាចជះឥទ្ធិពលយ៉ាងច្រើនទៅលើគោលនយោបាយ ។

អត្ថបទនេះពិនិត្យពីទំនាក់ទំនងរវាងភេទនៃមេគ្រួសារនៅជនបទ ហើយនិងអថេរសំខាន់ៗមួយចំនួន ទាក់ទិននឹងបញ្ហាដីធ្លី ដូចជា ទំហំដីកាន់កាប់ លទ្ធកម្មដីធ្លី ទ្រព្យសម្បត្តិនិងចំណូលគ្រួសារ ធនធានកំលាំងពលកម្ម ការមានស្រូវអង្ករហូបគ្រប់គ្រាន់ និងវិនិយោគលើផលិតកម្មស្រូវ ។ មានលំនាំសំខាន់ៗពីរ ដែលពិនិត្យឃើញតាមទិន្នន័យប្រមូលបាននៅដើមឆ្នាំ២០០៤ សម្រាប់អង្កេតមូលដ្ឋានលើការផ្ដល់កម្មសិទ្ធិដីធ្លី ដែលវិទ្យាស្ថាន CDRI បានធ្វើឡើងសំរាប់គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP) ។[១] លំនាំទី១ គឺគ្រួសារស្ត្រីមេគ្រួ តែងមានលទ្ធភាពប្រើប្រាស់និងគ្រប់គ្រង ទ្រព្យផលិតកម្មតិចជាងគ្រួសារបុរសមេគ្រួ នៅក្នុងគ្រប់ក្រុមកាន់កាប់ដី ។ ថ្វីបើលំនាំនេះ បានបញ្ជាក់គាំទ្រដល់ចំណាប់អារម្មណ៍ជាទូទៅថា នៅក្នុងសង្គមជនបទ គ្រួសារស្ត្រីមេគ្រួតែងងាយធ្លាក់ចូល និងជាប់ផុងជាងគេ នៅក្នុងភាពក្រីក្រក៏ដោយ ប៉ុន្តែលំនាំទី២ បង្ហាញពីភាពខុសគ្នាយ៉ាងច្រើនរវាង គ្រួសារស្ត្រីមេគ្រួមានចំណូលទាប និងមានចំណូលខ្ពស់ បើគិតតាមលទ្ធភាពប្រើប្រាស់និង គ្រប់គ្រងលើទ្រព្យផលិតកម្ម ។ ចំណុចនេះបង្ហាញថា គ្រួសារស្ត្រីមេគ្រួ បានប្រើប្រាស់យុទ្ធសាស្ត្ររកចិញ្ចឹមជីវិតខុសៗគ្នា អាស្រ័យទៅតាមទ្រព្យសម្បត្តិ និងកម្លាំងពលកម្មដែលគេមាន ។ ការសង្កេតឃើញទាំងពីរនេះ អាចជួយដល់អ្នកកសាងគោលនយោបាយអោយរចនារៀបចំ និងកំណត់មុខសញ្ញាអន្តរាគមន៍កាត់បន្ថយភាពក្រីក្រ បានកាន់តែប្រសើរថែមទៀត ។

## ការកាន់កាប់ដីធ្លី

ជាទូទៅ ចំនួន និងទំហំក្បាលដីកសិកម្មជាមធ្យម កើនឡើងជាបណ្ដើរៗស្របតាមទំហំដីកាន់កាប់សរុបតាមគ្រួសារ ។ លំនាំនេះឃើញមានទាំងសំរាប់គ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ ។ ទោះជាយ៉ាងនេះក្ដី ចំនួន និងទំហំក្បាលដីកាន់កាប់ដោយគ្រួសារស្ត្រីមេគ្រួ ជាមធ្យមមានតិចជាងគ្រួសារបុរសមេគ្រួ ។ តារាង ១ បង្ហាញថា គ្រួសារបុរសមេគ្រួកាន់កាប់ ៤,៤៤ក្បាលដី ក្នុងមួយគ្រួសារ ដែលមានទំហំ ០,៣៩ហិកតា/ក្បាលដី រីឯគ្រួសារស្ត្រីមេគ្រួ កាន់កាប់ជាមធ្យម ៣,៧៨ក្បាលដី ដែលមានទំហំជាមធ្យម ០,៣០ហិកតា/ក្បាលដី ។

*តារាង ១. ទិន្នន័យសង្ខេបពីដីកសិកម្មបែងចែកតាមយេនឌ័រ*

| ទំហំដី (ហិកតា) | ចំនួនគ្រួសារ | | ផ្ទៃដី/គ្រួសារ | | ក្បាលដី/គ្រួសារ | | ផ្ទៃដី/ក្បាលដី | |
|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| < 0.5 | 123 | 78 | 0.28 | 0.26 | 2.28 | 2.36 | 0.12 | 0.11 |
| 0.5 – 0.99 | 164 | 59 | 0.70 | 0.69 | 3.78 | 3.89 | 0.18 | 0.18 |
| 1.0 – 1.99 | 180 | 49 | 1.40 | 1.40 | 4.86 | 4.40 | 0.28 | 0.31 |
| 2.0 – 2.99 | 102 | 20 | 2.43 | 2.29 | 5.29 | 5.65 | 0.46 | 0.40 |
| > 3.0 | 113 | 19 | 5.36 | 4.59 | 6.32 | 5.89 | 0.76 | 0.77 |
| សរុប | 682 | 225 | 1.75 | 1.17 | 4.44 | 3.78 | 0.39 | 0.30 |

ទិន្នន័យអង្កេតមូលដ្ឋានក៏បង្ហាញដែរថា គ្រួសារស្ត្រីមេគ្រួ ៣៤% មានដីកសិកម្មតិចជាង ០,៥ហិកតា ធៀបនឹង ១៨% សំរាប់គ្រួសារបុរសមេគ្រួ ។ ដូចគ្នាដែរ គ្រួសារស្ត្រីមេគ្រួ ៦០% កាន់កាប់ដីតិចជាង ១ហិកតា ហើយសំរាប់គ្រួសារបុរសមេគ្រួ គឺ ៤២% ។ ផ្ទុយទៅវិញ គ្រួសារស្ត្រីមេគ្រួ ១៧% កាន់កាប់ដីច្រើនជាង ២ហិកតា រីឯគ្រួសារបុរសមេគ្រួ មានដល់ ៣១% ។ លំនាំនៃការបែងចែកដីនេះ ជះឥទ្ធិពលយ៉ាងច្រើនទៅលើផលិតភាព និងប្រាក់ចំណូលពីការធ្វើកសិកម្ម ។ ជារួម ការណ៍នេះបង្ហាញថា ការពុះចែកក្បាលដីកាន់តែតូចទៅៗ ទំនងជានឹងមានច្រើននៅខាងគ្រួសារស្ត្រីមេគ្រួ[២] រីឯការប្រមូលផ្ដុំ និងគួបបញ្ចូលគ្នានៃដីធ្លី ទំនងជាកើតមានភាគច្រើននៅខាងគ្រួសារបុរសមេគ្រួ ។ មតិទាំងពីរនេះត្រូវតែផ្ទៀងផ្ទាត់ថែមទៀតដោយការស្រាវជ្រាវ ដែលផ្ដោតជាពិសេសទៅលើគ្រួសារគ្រប់គ្រងដោយស្ត្រីមេម៉ាយនៅជនបទ ។

## ការទទួលបានដីធ្លី

របៀបនៃការទទួលបានដីធ្លី ក៏បង្ហាញពីកត្តាសំខាន់ៗជាច្រើនពាក់ព័ន្ធនឹងទំនាក់ទំនងរវាងយេនឌ័រនៃមេគ្រួសារ និងកម្មសិទ្ធិដីធ្លី ។ តារាង ២ បង្ហាញថា គ្រួសារស្ត្រីមេគ្រួដែលទទួលបានក្បាលដីពីរដ្ឋ មាន ៧០,៩% គឺខ្ពស់ជាងគ្រួសារបុរសមេគ្រួ (៥១,៣%) ។ ភាគរយគ្រួសារស្រីមេគ្រួដែលទទួលបានក្បាលដីតាមរយៈកេរ្ដិ៍មរតក (១១,%) មានកំរិតទាបខ្លាំងជាង គ្រួសារបុរសមេគ្រួ (២៤,៦%) ។ ភាពខុសគ្នានេះ គ្មានអ្វីគួរភ្ញាក់ផ្អើលទេ យោងតាមរបៀបរបបជាប្រពៃណីនៅជនបទកម្ពុជា ដែលដីធ្លីតែងប្រគល់ទៅអោយកូនប្រុស ។

*តារាង ២. ការទទួលបានដីធ្លី បែងចែកតាមយេនឌ័រ (%)*

| ទំហំដី (ហិកតា) | បានពីរដ្ឋ | | មរតក | | ទិញ | | ការរានដីព្រៃ | |
|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| < 0.5 | 39.5 | 73.1 | 43.1 | 19.4 | 14.9 | 6.5 | 2.5 | 1.1 |
| 0.5 – 0.9 | 52.0 | 71.6 | 29.6 | 6.7 | 15.7 | 16.4 | 2.6 | 4.9 |
| 1.0 – 1.9 | 58.7 | 77.9 | 21.5 | 6.9 | 14.9 | 8.3 | 4.9 | 6.9 |
| 2.0 – 2.9 | 51.5 | 73.5 | 18.5 | 12.4 | 18.5 | 6.2 | 11.4 | 8.0 |
| > 3.0 | 46.1 | 50.0 | 22.1 | 12.5 | 16.7 | 22.3 | 15.2 | 15.2 |
| សរុប | 51.3 | 70.9 | 24.7 | 11.0 | 16.1 | 11.6 | 7.8 | 6.3 |

* លោក Brett M. Ballard ជាទីប្រឹក្សាស្រាវជ្រាវជាន់ខ្ពស់ ហើយលោកស្រី Ingrid FitzGerald ជាទីប្រឹក្សាខាងយេនឌ័រនៅវិទ្យាស្ថាន CDRI ។ តារាងទិន្នន័យប្រើប្រាស់ក្នុងអត្ថបទនេះ ធ្វើឡើងដោយលោក សូ សុវណ្ណារិទ្ធិ ។ អ្នកនិពន្ធ សូមថ្លែងអំណរគុណផងដែរដល់លោក ភឹម រុនស៊ីណារិទ្ធិ ដែលបានជួយដល់ការវិភាគទិន្នន័យ ។

*តារាង ៣. ទ្រព្យសម្បត្តិ និងកម្លាំងពលកម្មគ្រួសារ (តម្លៃមធ្យមគិតជាម៉ឺនរៀល/គ្រួសារ)*

| ទំហំដី (ហ.ត) | បសុសត្វ * | | ទ្រព្យជាប់លាប់ | | ទ្រព្យជាប់លាប់ មិនសំរាប់ធ្វើកសិកម្ម | | ទ្រព្យធ្វើកសិកម្ម មិនមែនម៉ាស៊ីន | | ទ្រព្យធ្វើកសិកម្ម ជាម៉ាស៊ីន | | ពលកម្ម គ្រួសារ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| 0 | 54.7 | 41.3 | | | | | | | | | 4.1 | 4.6 |
| < 0.5 | 111.8 | 87.6 | 36.4 | 28.1 | 29.9 | 2.4 | 3.7 | 3.4 | 9.2 | 2.0 | 3.6 | 2.9 |
| 0.5 – 0.99 | 167.0 | 150.7 | 40.7 | 37.8 | 10.4 | 3.3 | 11.2 | 5.8 | 22.1 | 3.4 | 4.2 | 3.8 |
| 1.0 – 1.99 | 212.2 | 127.0 | 62.4 | 14.1 | 23.9 | 0.8 | 14.8 | 9.5 | 36.7 | 5.2 | 4.5 | 2.2 |
| 2.0 – 2.99 | 245.9 | 129.9 | 51.7 | 27.8 | 12.8 | 5.3 | 23.5 | 13.2 | 41.5 | 11.6 | 4.9 | 4.4 |
| > 3.0 | 309.4 | 318.7 | 60.6 | 43.5 | 24.6 | 22.3 | 40.2 | 20.2 | 45.9 | 29.6 | 5.1 | 4.4 |
| សរុប | 197.4 | 128.7 | 50.7 | 28.8 | 20.4 | 4.1 | 18.2 | 7.8 | 31.4 | 6.7 | 4.4 | 3.4 |

* N= *៨៨៨គ្រួសារ រាយការណ៍ពីការគ្រប់គ្រងលើបសុសត្វ*

តារាង ២ បង្ហាញថា គ្រួសារស្ត្រីមេគ្រួដែលទទួលបានក្បាលដីតាមរយៈការទិញ និងការរានដីព្រៃ គឺមានតិចជាង គ្រួសារបុរសមេគ្រួ ។ ដូច្នេះ គួបផ្សំគ្នាមក ភាគរយទាបនៃការផ្ទេរមរតក ការទិញ និងការរានដីព្រៃបង្ហាញថា គ្រួសារស្ត្រីមេគ្រួ មានលទ្ធភាពទទួលបានក្បាលដីបន្ថែម តិចជាងគ្រួសារបុរសមេគ្រួ លើកលែងតែគ្រួសារដែលមានដីចាប់ពី ៣ហិកតាឡើងទៅ ។ តារាង ៣ ជួយបញ្ជាក់ពីការសង្កេតឃើញនេះដោយបង្ហាញថា គ្រួសារស្ត្រីមេគ្រួនៅក្នុងក្រុមកាន់កាប់ដីនីមួយៗ ជាមធ្យមមានទ្រព្យសម្បត្តិ និងប្រាក់ចំណូល តិចជាងគ្រួសារបុរសមេគ្រួ ។ ទ្រព្យសម្បត្តិតិចជាង ជាពិសេសទ្រព្យសំរាប់ធ្វើកសិកម្ម និងកម្លាំងពលកម្មមនុស្សពេញវ័យ វាជាកំហិតកំណត់ចំនួនដីធ្លីដែលអាចធ្វើកសិកម្ម រឺរានយកបាន រឺឯប្រាក់ចំណូលទាប វាជាកំហិតកំណត់លើការទិញដីបន្ថែម ។

## ផលស្រូវគ្រប់គ្រាន់

តាមធម្មតា ផលស្រូវពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងទំហំដីកាន់កាប់ ។ ជាទូទៅ ភាគរយនៃគ្រួសារដែលផលិតស្រូវបានគ្រប់គ្រាន់ រឺមានអតិរេកតែងកើនឡើងទៅតាមទំហំដីកាន់កាប់ រីឯភាគរយគ្រួសារដែលត្រូវទិញស្រូវអង្ករសំរាប់បរិភោគចាប់ពី ៩ខែឡើងទៅក្នុងមួយឆ្នាំ វាថយចុះយ៉ាងខ្លាំងនៅពេលទំហំដីកាន់កាប់កើនឡើង ។ គ្រួសារកាន់កាប់ដីធំ ក៏មានប្រៀបជាច្រើនទៀតទៅលើគ្រួសារកាន់កាប់ដីតូច ។ ឧទាហរណ៍ គ្រួសារមានដី ៣ហិកតាឡើងទៅ តំណាងឱ្យ ២៣% នៃគ្រួសារដែលផលិតស្រូវមានអតិរេក ទោះបីនៅក្នុងគំរូតាង ពួកគេតំណាងឱ្យតែ ១៣% ក៏ដោយ ។ គ្រួសារមានដី ០,៥ហិកតា រឺតិចជាង (រួមទាំងអ្នកអត់ដី) តំណាងឱ្យ ៦,៨% នៃអ្នកផលិតស្រូវមានអតិរេក ប៉ុន្តែនៅក្នុងចំនួនសរុប ពួកគេតំណាងឱ្យ ២៧% ។ គ្រួសារអត់ដី តំណាងឱ្យ ៣៧% នៃគ្រួសារត្រូវទិញស្រូវទាំងអស់ ប៉ុន្តែពួកគេមានចំនួនស្មើនឹង ៦,៣% នៃគ្រួសារនៅក្នុងអង្កេតប៉ុណ្ណោះ ។

ចំនុចគួរអោយចាប់អារម្មណ៍គឺ គ្រួសារមានដីចាប់ពី ២ហិកតាឡើងទៅ មានចំនួនស្មើ ២៤% នៃគ្រួសារដែលត្រូវទិញស្រូវអង្ករសំរាប់ហូបទាំងអស់ ។ បើគិតមួយភ្លែត រឿងនេះហាក់ដូចមិនត្រឹមត្រូវទេ ពីព្រោះគេតែងរំពឹងថា គ្រួសារមានដីធំដូច្នេះ យ៉ាងហោចណាស់ក៏អាចផលិតស្រូវបានខ្លះដែរ ។ ការបាត់បង់ផលស្រូវបែបនេះ អាចពន្យល់មួយបែបថា មកពីមានសត្វល្អិត ទឹកជំនន់ និងការរាំងស្ងួតបំផ្លាញអស់ ។ មូលហេតុនេះក៏ជួយពន្យល់ថា ហេតុអ្វីបានជាអ្នកមានដីតូចៗជាច្រើននាក់ត្រូវទិញស្រូវអង្ករសំរាប់ហូប

*តារាង ៤. វត្តមានផលស្រូវគ្រប់ហូប*

| ទំហំដី (ហិកតា) | អតិរេក | | គ្រប់គ្រាន់ | | 7-10 ខែ | | 3-6 ខែ | | < 3 ខែ | | ទិញទាំងអស់ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| 0 | 5 | 0 | 3 | 0 | 0 | 0 | 0 | 0 | 0 | 1 | 32 | 20 | 40 | 21 |
| < 0.5 | 9 | 5 | 13 | 4 | 32 | 21 | 33 | 20 | 19 | 17 | 17 | 11 | 123 | 78 |
| 0.5 – 0.9 | 52 | 12 | 17 | 13 | 45 | 16 | 25 | 9 | 14 | 3 | 11 | 5 | 164 | 58 |
| 1.0 – 1.9 | 65 | 12 | 33 | 7 | 30 | 7 | 24 | 9 | 15 | 8 | 13 | 6 | 180 | 49 |
| 2.0 – 2.9 | 40 | 10 | 15 | 1 | 13 | 3 | 13 | 0 | 7 | 3 | 14 | 3 | 102 | 20 |
| > 3.0 | 56 | 7 | 17 | 2 | 15 | 1 | 11 | 4 | 9 | 2 | 5 | 3 | 113 | 19 |
| Total N | 227 | 46 | 98 | 27 | 135 | 48 | 106 | 42 | 64 | 34 | 92 | 48 | 722 | 245 |
| % total F/M | 31.4 | 18.8 | 13.6 | 11.0 | 18.7 | 19.6 | 14.9 | 17.1 | 8.9 | 13.9 | 12.7 | 19.6 | | |
| សរុប | 273 | | 125 | | 183 | | 148 | | 98 | | 140 | | 967* | |

*N = *បាត់អស់ ៣ គ្រួសារ*

ទាំងអស់ ។ មតិនេះត្រូវបានបញ្ជាក់គាំទ្រ ដោយទិន្នន័យពាក់ព័ន្ធជាមួយ វិបត្តិ/បញ្ហាគ្រួសារ ដែលបង្ហាញថា ៦៧គ្រួសារ នៅក្នុងក្រុមអង្កេត LMAP ក្នុងនេះមានទាំង ១៥គ្រួសារដែលមានដីកសិកម្ម ៣ហិកតា រឺច្រើនជាងផង គឺធ្លាប់ខូចខាតផលដំណាំដោយសារសត្វល្អិត ។ មាន ៣៩៨គ្រួសារ (៧១ គ្រួសារមានដីដល់ ៣ហិកតា រឺច្រើនជាង) បានរាយការណ៍ពីការខូចផលដំណាំ ដោយសារទឹកជំនន់ និងគ្រោះរាំងស្ងួត ។ គួរចងចាំថា នៅឆ្នាំ២០០៣ ដែល ជាឆ្នាំចុះប្រមូលទិន្នន័យកសិកម្ម មានគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតនៅ តាមតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា រួមទាំងតំបន់មួយចំនួននៅក្នុងគំរូតាង អង្កេតនេះផង ។

ទិន្នន័យពីវត្តមានផលស្រូវគ្រប់ហូបបង្ហាញថា គ្រួសារបុរសមេគ្រួច្រើនមាន ប្រៀបល្អជាងគ្រួសារស្ត្រីមេគ្រួ ។ ឧទាហរណ៍ គ្រួសារបុរសមេគ្រួតំណាងឱ្យ ៨៣,២%នៃគ្រួសារមានអតិរេកផលស្រូវ ប៉ុន្តែមានចំនួនត្រឹម ៧៤,៦% នៃ គ្រួសារទាំងអស់ប៉ុណ្ណោះ ។ គ្រួសារស្ត្រីមេគ្រួ មានចំនួនស្មើនឹង ៣៤% នៃ គ្រួសារត្រូវទិញស្រូវអង្ករហូបពេញមួយឆ្នាំ ប៉ុន្តែមានត្រឹម ២៥% នៃគ្រួសារ បានចុះអង្កេតប៉ុណ្ណោះ ។ គ្រួសារស្ត្រីមេគ្រួ តំណាងឱ្យ ៥៣,១% នៃគ្រួសារ មានផលស្រូវគ្រប់ហូបសំរាប់ ៣ខែ រឺតិចជាង និង ៣៩,៦% នៃគ្រួសារ មានផលស្រូវគ្រប់ហូបសំរាប់ ៣ ទៅ ៦ខែ ។ តួលេខនេះអាចបកស្រាយបាន ថា មកពីគ្រួសារស្ត្រីមេគ្រួមានដីកាន់កាប់តូចៗ ទ្រព្យសម្បត្តិតិចតួច និង កម្លាំងពលកម្មមនុស្សពេញវ័យតិច ។

## ចំណាយលើផលិតកម្មស្រូវ

បន្ថែមពីលើដីធ្លី ទ្រព្យមូលធនផ្សេងទៀត និងកម្លាំងពលកម្ម តួលេខ ខុសៗគ្នានៃអ្នកមានផលស្រូវគ្រប់ហូប នៅតាមក្រុមអ្នកកាន់កាប់ដីខុសៗគ្នា អាចបកស្រាយបានតាមរយៈទំហំវិនិយោគលើផលិតកម្មស្រូវ ។ តារាង ៥ បង្ហាញថា វិនិយោគលើផលិតកម្មស្រូវជាមធ្យម ជាទូទៅកើនឡើងទៅតាម ទំហំដីកាន់កាប់ ។ លំនាំនេះអាចសង្កេតឃើញទាំងសំរាប់គ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ នៅតាមគ្រប់ទំហំដីកាន់កាប់ ។ គួរកត់សំគាល់ជាសំខាន់ ថា នៅតាមក្រុមកាន់កាប់ដីនីមួយៗ គ្រួសារបុរសមេគ្រួជាទូទៅបានវិនិយោគ ទៅលើដីកាន់កាប់ ច្រើនជាងគ្រួសារស្ត្រីមេគ្រួ លើកលែងក្នុងក្រុមកាន់កាប់ ដីធំបំផុត ដែលគ្រួសារស្ត្រីមេគ្រួបានវិនិយោគជាមធ្យមប្រហែល ៦០ម៉ឺនរៀល /គ្រួសារ ធៀបនឹងត្រឹម ៥០ម៉ឺនរៀល សំរាប់គ្រួសារបុរសមេគ្រួ ។ ដោយ សារ គ្រួសារស្ត្រីមេគ្រួជាទូទៅមានកម្លាំងពលកម្មតិច ដូច្នេះពួកគេតែងហ៊ាន ចំណាយសោហ៊ុយប៉ះប៉ូវកង្វះខាតនេះ នៅពេលពួកគេមានលទ្ធភាព ។

## ការពិភាក្សា

ទិន្នន័យអង្កេតមូលដ្ឋានពីការចុះបញ្ជីដីធ្លីនៅជនបទ បង្ហាញរូបភាពដ៏ សំខាន់មួយពីភាពខុសគ្នានៃទ្រព្យសម្បត្តិ របស់គ្រួសារស្ត្រីមេគ្រួ និងគ្រួសារ បុរសមេគ្រួ នៅក្នុងក្រុមដីកាន់កាប់នីមួយៗ និងរវាងក្រុមដីកាន់កាប់ខុសៗគ្នា និងបញ្ជាក់គាំទ្រដល់ការសិក្សាដទៃទៀត ដែលគូសរំលេចពីការចាញ់ប្រៀប ផ្សេងៗដែលគ្រួសារស្ត្រីមេគ្រួត្រូវជួបប្រទះ ក្នុងការកាន់កាប់ដីឱ្យមានសុវត្ថិភាព និងការរកចិញ្ចឹមជីវិត ។ ប៉ុន្តែត្រង់ចំនុចនេះ មានកង្វះទិន្នន័យសំរាប់សិក្សា ពីការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ដូចជា នៅពេលណាដែល ស្ត្រីក្លាយជា មេគ្រួសារមេម៉ាយ ហើយមានអ្វីកើតឡើងចំពោះដីកាន់កាប់ និង ទ្រព្យ ផ្សេងទៀតរបស់ពួកគេ? យើងអាចសន្និដ្ឋានបានថា ជាមធ្យមគ្រួសារស្ត្រីមេគ្រួ ទទួលបានដីតិចជាងនៅពេលបែងចែកដីនៅឆ្នាំ១៩៨៩ ប៉ុន្តែតាំងពីនោះមក តើវាវិវត្តយ៉ាងណាទៀត?

*តារាង ៥. ធាតុចូលសំរាប់ផលិតកម្មស្រូវ (ម៉ឺនរៀល/គ្រួសារ)*

| ធាតុចូល | < .5 | | 0.5 – 0.99 | | 1.0 – 1.99 | | 2.0 - 2.99 | | ≥ 3.0 | | សរុបជាមធ្យម | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | | |
| ជីគីមី | 5.8 | 5.7 | 10.6 | 8.7 | 12.0 | 8.3 | 13.6 | 8.9 | 17.6 | 32.7 | 11.21 | |
| ថ្នាំសំលាប់សត្វល្អិត | 1.4 | .8 | 2.1 | 1.2 | 2.0 | 1.1 | 1.5 | 1.5 | 3.1 | 3.1 | 2.06 | |
| បូមទឹក | 3.2 | 2.7 | 4.0 | 4.0 | 5.1 | 4.1 | 7.5 | 3.0 | 11.5 | 15.0 | 5.59 | |
| ពលកម្មរៀបចំដី | 4.6 | 3.1 | 6.7 | 5.2 | 11.6 | 7.1 | 10.6 | 5.5 | 18.4 | 17.3 | 9.01 | |
| ពលកម្មស្ទូង | 6.8 | 5.7 | 9.2 | 8.3 | 11.8 | 8.8 | 14.5 | 11.1 | 22.5 | 33.5 | 12.2 | |
| ពលកម្មច្រូតកាត់ | 5.3 | 3.4 | 6.2 | 4.0 | 8.3 | 5.4 | 12.1 | 9.9 | 13.5 | 18.3 | 8.46 | |
| បោកស្រូវ | 2.7 | 2.3 | 2.8 | 2.3 | 3.9 | 3.2 | 5.8 | 3.6 | 6.7 | 9.3 | 4.2 | |
| ជួសជុល | 1.5 | 1.1 | 2.2 | 1.6 | 2.3 | 2.4 | 1.7 | .95 | 1.9 | 15.0 | 2.07 | |
| ដឹកជញ្ជូន | 1.8 | 2.0 | 2.7 | 2.6 | 3.2 | 2.6 | 3.5 | 1.9 | 6.6 | 3.9 | 3.23 | |
| ជួលដី | 7.5 | | 6.1 | 1.7 | 10.8 | | 6.0 | | 10.9 | | 7.7 | |
| ជួលសត្វអូសទាញ | .2 | 5.0 | 4.9 | | 3.2 | 5.0 | | 6.0 | 10.0 | 1.5 | 4.48 | |
| ផ្សេងៗ | 4.6 | .97 | 4.4 | 5.5 | 10.6 | 20.0 | 3.1 | 10.0 | 7.4 | 6.3 | 7.2 | |
| សរុប | 14.4 | 10.8 | 23.1 | 17.0 | 34.4 | 20.0 | 32.8 | 25.0 | 50.7 | 60.2 | 30.7 | 19.8 |
| **សរុប** | 13.03 | | 21.57 | | 31.77 | | 31.6 | | 51.98 | | 28.2 | |

គេតែងគិតថា គ្រួសារស្ត្រីមេគ្រួនៅជនបទ មានស្ថានភាពងាយរងគ្រោះបំផុត និងងាយធ្លាក់ក្នុងភាពក្រីក្រ ហើយគំនិតនេះមានការបញ្ជាក់គាំទ្រពីការសិក្សាវាយតម្លៃពីភាពក្រីក្រដោយមានការចូលរួមរបស់ CDRI (PPA) នៅតំបន់ទន្លេសាបដែលរកឃើញថា គ្រួសារស្ត្រីមេគ្រួភាគច្រើនជាអ្នកក្រ រឺក្រណាស់នៅក្នុងគ្រប់ភូមិសិក្សា ទោះពួកគេមានរបបចិញ្ចឹមជីវិតបែបណាក្តី ។ ម្យ៉ាងទៀតនៅតាមតំបន់ជាច្រើន អ្នកភូមិរាយការណ៍ថា គ្រួសារស្ត្រីមេគ្រួក្រីក្រ និងក្រីក្រណាស់នៅឆ្នាំ២០០៥ គឺឃើញមានច្រើនជាងនៅឆ្នាំ២០០០ ។

អ្នកវិភាគអន្តរជាតិ និងការសិក្សាថ្មីៗរបស់កម្ពុជា មិនបានយល់ស្របតាមលទ្ធផលរកឃើញនេះទេ[៣] ដោយផ្តល់មតិថា ថ្វីបើគ្រួសារស្ត្រីមេគ្រួច្រើនតែមានជីវភាពលំបាកជាងគ្រួសារបុរសមេគ្រួ ប៉ុន្តែមានការប្រែប្រួលខុសគ្នាជាច្រើននៃប្រាក់ចំណូល ចំណាយប្រើប្រាស់ និងរបាយទ្រព្យសម្បត្តិ នៅក្នុងចំណោមគ្រួសារស្ត្រីមេគ្រួ ។ ឧទាហរណ៍ ការសិក្សាពីការចាកផុតពីភាពក្រីក្រ (MOPS) របស់ CDRI បង្ហាញថា គ្រួសារស្ត្រីមេគ្រួដែលជាប់ផុងក្នុងភាពក្រីក្រដ៏រ៉ាំរ៉ៃ មានច្រើនជាងគេក៏ពិតមែន ប៉ុន្តែគ្រួសារដែលអាចចាកផុតពីភាពក្រីក្រ រឺក្លាយជាអ្នកធូរធារ ក៏មានច្រើនគួរសមដែរ ។ គិតជាសរុបគ្រួសារស្ត្រីមេគ្រួរកប្រាក់ចំណូលបានតិច និងកាន់កាប់ដីតូចជាងគ្រួសារបុរសមេគ្រួក៏ពិតមែន ប៉ុន្តែគ្រួសារស្ត្រីមេគ្រួដែលធូរធារ គឺមានប្រាក់ចំណូល និងទ្រព្យសម្បត្តិ ប្រហាក់ប្រហែលគ្នានឹងគ្រួសារបុរសមេគ្រួដែលមានជីវភាពធូរធារដែរ ។ គ្រួសារស្ត្រីមេគ្រួដែលមានជីវភាពលានឡើង ក៏ច្រើនតែជាគ្រួសារគ្មានដីកសិកម្មដែរ ដោយពួកគេពឹងផ្អែកលើប្រភពចំណូលដទៃទៀតដែលមិនមែនជាការងារកសិកម្ម ដើម្បីចាកផុតពីភាពក្រីក្រ ។[៤]

ទិន្នន័យអង្កេតមូលដ្ឋានស្តីពីការចុះបញ្ជីដីធ្លីនៅជនបទ បង្ហាញថាធៀបនឹងគ្រួសារបុរសមេគ្រួ គ្រួសារស្ត្រីមេគ្រួ ច្រើនតែចាញ់ប្រៀបបើគិតតាមទំហំដីកាន់កាប់ និងលំនាំនៃការទទួលបានដីធ្លី ហើយរឿងនេះបណ្តាលមកពីប្រវត្តិនៃការបែងចែកដី កង្វះធនធានមនុស្ស និងកង្វះទ្រព្យសម្បត្តិ ។ ដូចក្នុង MOPS ដែរ ទិន្នន័យអង្កេតមូលដ្ឋាននៅជនបទ បង្ហាញពីភាពខុសគ្នាយ៉ាងច្រើនរវាងគ្រួសារស្ត្រីមេគ្រួទាំងទាំ ដូច្នេះពួកគេមិនមែនសុទ្ធតែក្រនោះទេ ។ ឧទាហរណ៍ តារាង ១ បង្ហាញថា ១៧% នៃគ្រួសារស្ត្រីមេគ្រួដែលបានចុះអង្កេត មានដីកាន់កាប់ ២ហិកតា រឺច្រើនជាង ។ តារាង ៣ បង្ហាញពីគំលាតដ៏ធំរវាង គ្រួសារកាន់កាប់ដីតូច និងគ្រួសារកាន់កាប់ដីធំ បើពិនិត្យតាមតម្លៃបសុសត្វ និងទ្រព្យមូលធន ។ តារាង ៥ បង្ហាញថា គ្រួសារកាន់កាប់ដីធំវិនិយោគលើផលិតកម្មស្រូវ ស្ទើរតែបួនដងច្រើនជាងគ្រួសារកាន់កាប់ដីតូច ។

លទ្ធផលរកឃើញទាំងនេះ អាចមានប្រយោជន៍ច្រើនដល់ការតម្រង់ទិសគោលនយោបាយអោយមានប្រសិទ្ធភាព ។ ឧទាហរណ៍ ការផ្តួចផ្តើមគំនិតចុះបញ្ជីដីធ្លី គួរតែបន្តប្រឹងប្រែងជាពិសេស ដើម្បីធានាអោយគ្រួសារស្ត្រីមេគ្រួទទួលបានកម្មសិទ្ធិដីធ្លី ។ យោងតាមលំនាំបែងចែកមរតកទៅតាមយេនឌ័រ និង សមត្ថភាពតិចជាង ដើម្បីរក្សាដីកាន់កាប់បច្ចុប្បន្ននិងទទួលបានដីថ្មី យើងឃើញថា សុវត្ថិភាពកម្មសិទ្ធិមានសារៈសំខាន់ណាស់សំរាប់ឱ្យគ្រួសារទាំងនេះអាចការពារទ្រព្យសម្បត្តិដែលមានស្រាប់ និងបង្កើនលទ្ធភាពទទួលបានឥណទានផ្លូវការ ។ លទ្ធភាពទទួលបានឥណទានផ្លូវការ វាសំខាន់ជាពិសេសដោយជួយសំរួលការវិនិយោគច្រើនថែមទៀតទៅក្នុងអាជីវកម្មតូចៗ ដែលជាប្រភពកាន់តែសំខាន់សំរាប់ប្រាក់ចំណូលរបស់គ្រួសារស្ត្រីមេគ្រួ ។ ប័ណ្ណកម្មសិទ្ធិដី អាចជួយឱ្យស្ត្រីជាមេគ្រួសារអាចលក់ដីខ្លួនបានថ្លៃខ្ពស់ ហើយទាញយកចំណេញពីឱកាសល្អៗដើម្បីរកប្រាក់ចំណូលពីមុខរបរក្រៅកសិកម្ម ។ ហើយទោះបីវិធីនេះវាបង្កើនភាពអត់ដីធ្លី រឺស្ទើរអត់ដីធ្លីក្នុងចំណោមគ្រួសារស្ត្រីមេគ្រួក្តី ប៉ុន្តែវាមិនមែនជាលទ្ធផលអវិជ្ជមានទេ បើសិនគេអាចរកបានការងារ/អាជីវកម្មដែលអាចរស់រានបាន ។

ការពិភាក្សាខាងលើ បានបង្ហាញពីតម្រូវការស្រាវជ្រាវបន្ថែមពីការកាន់កាប់ដីនៅកម្ពុជា ដោយផ្តោតជាពិសេសលើបញ្ហាយេនឌ័រ ។ ទិដ្ឋភាពសំខាន់មួយនៃការស្រាវជ្រាវបែបនេះគឺត្រូវពិនិត្យថា តើប័ណ្ណកម្មសិទ្ធិដីបានកែលំអនិងពង្រឹងសុវត្ថិភាពកាន់កាប់ដីរបស់ស្ត្រី (ទាំងនៅក្នុងគ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ) ព្រមទាំងសុខមាលភាពរបស់គ្រួសារស្ត្រីមេគ្រួរឺទេ ។ មួយផ្នែកដ៏សំខាន់នៃការស្រាវជ្រាវ ត្រូវផ្តោតលើយុទ្ធសាស្ត្ររកចិញ្ចឹមជីវិត និងប្រភពប្រាក់ចំណូលដោយយោងតាមភេទនៃមេគ្រួសារ ។ ក្នុងករណីទាំងពីរនេះ ត្រូវប្រើវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ ពីព្រោះបញ្ហាពាក់ព័ន្ធជាច្រើនអាចមានលក្ខណៈរសើប និងស្មុគស្មាញច្រើន ដូច្នេះមិនងាយនឹងក្តាប់បានដោយប្រើឧបករណ៍ស្រាវជ្រាវបែបបរិមាណនោះទេ ។ ពិតហើយក្នុងរឿងសិទ្ធិ និងសុវត្ថិភាពកាន់កាប់ដី ក្នុងនេះមានទាំងការប្រមូលផ្តុំដីធ្លី និងការពុះបំបែកក្បាលដីកាន់តែតូចទៅៗផង មានបញ្ហាជាច្រើនជាប់ពាក់ព័ន្ធនឹងយេនឌ័រ ហើយមានលក្ខណៈដើមបែបសង្គម និងវប្បធម៌ផង ដូច្នេះត្រូវតែប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវមានលក្ខណៈច្នៃប្រឌិតខ្ពស់ ។

## កំណត់សំគាល់

១. ទិន្នន័យការអង្កេតគ្របដណ្តប់លើ ៩៧០គ្រួសារនៅជនបទ ក្នុង ៣២ភូមិក្នុងខេត្ត LMAP ទាំង៤ គឺ កំពង់ចាម កំពង់ធំ ក្រុងព្រះសីហនុ និងតាកែវ ដោយក្នុងនេះ មាន ៦៣គ្រួសាររាយការណ៍ថាគ្មានដីកសិកម្ម ។ ដូច្នេះទិន្នន័យនេះសំដៅលើការកាន់កាប់ដីរបស់ ៩០៧គ្រួសារគំរូតាង ដែលមាន ៦៨២គ្រួសារបុរសមេគ្រួ (៧៥,២%) និង ២២៥គ្រួសារស្ត្រីមេគ្រួ (២៤,៨%) ។

២. ការបកស្រាយមួយ គឺអាចមកពីមូលហេតុដែលគ្រួសារត្រូវមានមេគ្រួសារជាស្ត្រី ។ ឧ. ស្ត្រីក្លាយជាមេម៉ាយដោយប្តីស្លាប់ ប្តីលែង រឺប្តីចាកចោល អាចបាត់បង់អស់ទ្រព្យផលិតកម្ម មានទាំងដីធ្លីផង (Fitzgerald 2007)

៣. មើល Chant (២០០៣) សំរាប់ការពិភាក្សាពីបញ្ហាជាប់ទាក់ទងនឹងការសន្មតថា គ្រួសារស្ត្រីមេគ្រួ គឺងាយរងគ្រោះ និង/រឺក្រីក្រ ។ មើល Urashima et al. (2007) សំរាប់ការវិភាគពីភាពខុសគ្នារវាងគ្រួសារស្ត្រីមេគ្រួនៅកម្ពុជា ដោយប្រើទិន្នន័យ CSES ឆ្នាំ២០០៤ ។ ការវិភាគនេះបង្ហាញថា គ្រួសារស្ត្រីមេគ្រួដែលគ្មានកម្លាំងមនុស្សប្រុសពេញវ័យ និងមានអ្នកនៅក្នុងបន្ទុកច្រើន គឺតែងតែក្រីក្រជាង គ្រួសារដែលមានកម្លាំងមនុស្សប្រុសពេញវ័យ និងមានអ្នកនៅក្នុងបន្ទុកតិចទាក់ ។

៤. ការបកស្រាយមួយចំពោះភាពផ្ទុយគ្នា រវាងលទ្ធផលនៅក្នុងអង្កេតមូលដ្ឋានពីការចុះបញ្ជីដីធ្លីជនបទ ហើយនិង MOPS មួយផ្នែក និង PPA មួយផ្នែកទៀត វាជាប់ទាក់ទិននឹងវិធីសាស្ត្រស្រាវជ្រាវ ។ PPA ផ្តោតលើគ្រួសារ និងសហគមន៍ក្រីក្រ ហើយប្រើវិធីសាស្ត្របែបគុណវិស័យ រីឯ MOPs បានរួមបញ្ចូលគ្រួសារ និងសហគមន៍ក្រីក្រ និងមិនក្រ ទៅក្នុងគំរូតាងរបស់ខ្លួន ។ MOPs បានប្រមូលផ្តុំទិន្នន័យបែបបរិមាណលើទ្រព្យសម្បត្តិ និងការចំណាយរបស់គ្រួសារ ដែលអាចធ្វើការប្រៀបធៀបគ្នាបានរវាងគ្រួសារបុរសមេគ្រួ និងគ្រួសារស្ត្រីមេគ្រួ ។

## ឯកសារយោង

*សូមមើលឯកសារយោងក្នុងអត្ថបទភាសាអង់គ្លេស*